A3PCON
ASIAN PACIFIC POLICY & PLANNING COUNCIL

# មគ្គុទេសក៍អ្នកបោះឆ្នោតសម្រាប់ វិច្ឆិកា 2020

| | |
|---|---|
| **សំណើ 14**<br>បណ្ណធានារដ្ឋាភិបាលសម្រាប់ស្រាវជ្រាវកោសិកាដើម | **គ្មានការសម្រេច** -- សំណើលេខ 14 នឹងចេញបណ្ណធានារដ្ឋាភិបាលចំនួន $5.5 ប៊ីលានដុល្លារ អោយវិទ្យាស្ថានឱសថបុនភាវកម្មនៃរដ្ឋកាលីហ្វរញ៉ា (California Institute of Regenerative Medicine (CIRM)។ 9.2% នៃប្រាក់ឧបត្ថម្ភនេះ នឹងចំណាយលើការស្រាវជ្រាវ, ការពិសោធ, និងកម្មវិធីផ្សេងៗ ដែលទាក់ទងនឹងកោសិកាដើម។ នៅខណ:ដែលស្ថានភាពនយោបាយ និងសេដ្ឋកិច្ច ទាក់ទងនឹងការស្រាវជ្រាវកោសិកាដើមនេះ មានការប្រែប្រួលយ៉ាងខ្លាំងនោះ, តាមទំនង ប្រាក់ឧបត្ថម្ភ នឹងបានមកពីប្រភពវិនិយោគ រដ្ឋាភិបាលសហព័ន្ធ និងវិនិយោគិនឯកជន។ |
| **សំណើ 15**<br>ពន្ធលើទ្រព្យសម្បត្តិពាណិជ្ជកម្ម និងឧស្សាកម្ម សម្រាប់ការផ្តួចផ្តើមគំនិតផ្គត់ផ្គង់ដល់ការអប់រំ និងរដ្ឋាភិបាលមូលដ្ឋាន | **គាំទ្រ** - សំណើលេខ 15 តម្រូវអោយមានការគិតពន្ធតាមតម្លៃទីផ្សារ នៅលើទ្រព្យសម្បត្តិពាណិជ្ជ និងឧស្សាហកម្ម --ដែលរដ្ឋាភិបាលមូលដ្ឋាន នឹងវាយតម្លៃយ៉ាងហោចណាស់ រៀងរាល់បីឆ្នាំម្តង។ ទ្រព្យសម្បត្តិលំនៅឋាន និងម្ចាស់ពាណិជ្ជកម្ម ដែលមានទ្រព្យសម្បត្តិក្រោម $3 លាន នឹងបន្តបង់ពន្ធនៅលើតម្លៃដែលគេបានទិញ។ គំនិតផ្តួចផ្តើមនេះ នឹងផ្តល់ទឹកប្រាក់ $8-12.5 ប៊ីលានដុល្លារ សម្រាប់ផ្គត់ផ្គង់ដល់រដ្ឋាភិបាលរដ្ឋ និងមូលដ្ឋាន, ជាមួយនឹង 40% ផ្តាច់មុខអោយទៅសាលារៀនសង្កាត់ និងមហាវិទ្យាល័យសហគមន៍។ |
| **សំណើ 16**<br>ធ្វើនិរាករណ៍សំណើ 209<br>វិសោធនកម្មចំណាត់ការជាវិជ្ជមាន | **គាំទ្រ** – សំណើលេខ 16 នឹងធ្វើនិរាករណ៍សំណើ 209 ដែលជាការហាមឃាត់តាមរដ្ឋធម្មនុញ្ញ ចំពោះចំណាត់ការជាអវិជ្ជមាន ដែលផ្អែកទៅលើពូជសាសន៍ និង ភេទ។ ការសិក្សាថ្មីៗមាន បានបង្ហាញអោយឃើញអំពីរបៀបដែលសំណើ 209 បណ្តាលអោយមានការធ្លាក់ចុះ ជិត 12% នៃក្រុមនិស្សិត ដែលខ្វះភាពតំណាង នៅបរិវេណសាកលវិទ្យាល័យ UC នានា រួមទាំងនិស្សិតវិទ្យាល័យស្បែកខ្មៅ និងឡាតាំង ដែលមានគុណវុឌ្ឍិខ្ពស់ ប៉ុន្តែត្រូវបានបដិសេធ។ វានឹងពង្រីកឱកាសស្មើគ្នា ដល់ពលរដ្ឋកាលីហ្វរញ៉ាទាំងអស់, បង្កើនសិទ្ធិ សម្រាប់ទទួលបានប្រាក់ឈ្នួលសមរម្យ, ការងារល្អ, គុណភាពសាលា សម្រាប់គ្រប់គ្នា។ វាប្រឆាំងនឹងការរើសអើងប្រាក់ឈ្នួល និងរើសអើងពូជសាសន៍ជាប្រព័ន្ធ, បើកឱកាសសម្រាប់នារី និងប្រជាជនស្បែកពណ៌។ |
| **សំណើ 17**<br>វិសោធនកម្មលើការស្តារសិទ្ធិបោះឆ្នោតសម្រាប់ពិរុទ្ធជន ដែលត្រូវបានដោះលែងក្រោមលក្ខខ័ណ្ឌ | **គាំទ្រ** – សំណើ 17 ស្តារសិទ្ធិបោះជូនពិរុទ្ធជន ដែលត្រូវបានកាត់ទោស ហើយត្រូវបានដោះលែងក្រោមលក្ខខ័ណ្ឌ។ ការស្តារសិទ្ធិបោះឆ្នោតរបស់គេឡើងវិញ គឺជាផ្នែកដ៏សំខាន់មួយ សម្រាប់បញ្ចប់ការគាបសង្កត់អ្នកបោះឆ្នោត ហើយនឹងនាំសហរដ្ឋអាមេរិក កាន់តែខិតជិតរបបប្រជាធិបតេយ្យតំណាងមួយ។ |
| **សំណើ 18**<br>វិសោធនកម្មលើការបោះឆ្នោតបឋមសម្រាប់ជនអាយុ ១៧ ឆ្នាំ | **គាំទ្រ** – សំណើលេខ 18 នឹងអាចអនុញ្ញាតអោយយុវជន 200,000 នាក់ ក្នុងរដ្ឋកាលីហ្វរញ៉ា បោះឆ្នោត នៅក្នុងពេលបោះឆ្នោតបឋម ឬ ការបោះ ឆ្នោតពិសេស ... និងអនុញ្ញាតអោយយុវជន AANHPI អាយុ 17 ឆ្នាំ ប្រមាណពី 30,00 ទៅ 50,000 អាចបោះ ឆ្នោត។ បច្ចុប្បន្ននេះ មានរដ្ឋចំនួន ១៨ និង DC (District of Columbia) អនុញ្ញាតអោយយុវជនអាយុ ១៧ ឆ្នាំ ទាំងឡាយ ដែលនឹងឈានចូលអាយុ ១៨ ឆ្នាំ នៅពេលបោះឆ្នោតសាកលនោះ បោះឆ្នោតនៅក្នុងការបោះឆ្នោតបឋម។ |
| **សំណើ 19**<br>វិសោធនកម្មលើការផ្ទេរពន្ធទ្រព្យសម្បត្តិ, ការលើកលែង, និងចំណូល សម្រាប់ ភ្នាក់ងារគ្រប់គ្រងភ្លើងឆេះព្រៃ និង ខោនទី | **គ្មានការសម្រេច** – សំណើ លេខ ១៩ អនុញ្ញាតអោយអ្នកបង់ពន្ធស្របច្បាប់ មានសិទ្ធិផ្ទេរការវាយតម្លៃពន្ធ ទៅកាន់ផ្ទះថ្លៃជាងនៅក្នុងរដ្ឋ។ វាអនុញ្ញាតផងដែរ នូវការផ្ទេរការវាយតម្លៃពន្ធ ចំនួនដល់ទៅ បីដង សម្រាប់មនុស្សអាយុលើស 55, មនុស្សមានពិការភាពធ្ងន់ធ្ងរ ឬអ្នករងគ្រោះដែលរួចផុតពីមហន្តរាយ។ លើសពីនេះទៀត វាតម្រូវអោយផ្ទះដែលបានមកតាមការស្នងមរតក ដែលមិនមែនជាលំនៅឋានចម្បងនោះ ត្រូវធ្វើការវាយតម្លៃឡើងវិញ និងគិតពន្ធតាមតម្លៃទីផ្សារ ហើយបែងចែកប្រាក់ចំណូល ដែលបានមកពីសំណើនេះអោយទៅភ្នាក់ងារគ្រប់គ្រងភ្លើងឆេះព្រៃ និង ខោនទី។ |
| **សំណើ 20**<br>ការកាត់ទោសឧក្រិដ្ឋកម្ម, ការដោះលែងក្រោមលក្ខខ័ណ្ឌ, និងគំនិតផ្តួចផ្តើមប្រមូល DNA | **ប្រឆាំង** – សំណើលេខ 20 នឹងលុបចោលនូវសិទ្ធិរបស់ជនល្មើសអហិង្សា ក្នុងការទទួលកម្មវិធីដោះលែងក្រោមលក្ខខ័ណ្ឌ បន្ទាប់ពីគេបានបំពេញតាមការកាត់ទោសអោយជាប់ឃុំពេញអណត្តិ ពីបទល្មើសដំបូងរបស់គេ។ វាក៏នឹងផ្លាស់ប្តូរផងដែរ នូវការចោទប្រកាន់ពីបទមជ្ឈឹម ទៅជាបទឧក្រិដ្ឋចំពោះចោរកម្ម ចាប់ពី $250 - $900 ហើយតម្រូវអោយជនល្មើស ប្រគល់គំរូ DNA សម្រាប់ដាក់ចូល មូលទិន្នន័យរបស់រដ្ឋ។ សំណើលេខ ២០ នឹងបង្កើនចំនួនទន្ទិតនៅតាមគុកខោនទី។ ដោយសារចំនួន AANHPIs ដែលជាប់ពន្ធនាគារ បានកើនឡើងក្នុងរយ:ពេលប៉ុន្មានឆ្នាំចុងក្រោយនេះ, វានឹងនាំអោយមានការផ្តន្ទាទោសឧក្រិដ្ឋ និងការនិរទេសបន្ថែមទៀត។ |

A3PCON
ASIAN PACIFIC POLICY & PLANNING COUNCIL

| | |
|---|---|
| **សំណើ 21**<br>គំនិតផ្តួចផ្តើ ត្រួតពិនិត្យការជួលផ្ទះមូលដ្ឋាន | **គាំទ្រ –** សំណើ 21 នឹងជំនួសច្បាប់ Costa-Hawkins Rental Housing Act។ គំនិតផ្តួចផ្តើមនេះ អនុញ្ញាត រដ្ឋាភិបាលមូលដ្ឋាន អនុម័តច្បាប់ត្រួតពិនិត្យ ការជួលយូនិតលំនៅឋាន ដែលបច្ចុប្បន្នកំពុងត្រូវបានលើកលែង។ ការលើកលែងទាំងនេះ គឺសម្រាប់យូនិតលំនៅឋាន ដែលត្រូវបានគេចូលរស់នៅ 15 ឆ្នាំ ដំបូង ដែលមានម្ចាស់ផ្ទះជាពលរដ្ឋ ដែលពុំមានយូនិតលំនៅឋានពីរផ្សេងគ្នា -- ដូចជាផ្ទះសម្រាប់គ្រួសារមួយ (single-family homes) និង duplexes ឬផ្ទះល្វែងសហគមន៍ និងខុនដូ។ គំនិតផ្តួចផ្តើមនេះ នឹងតម្រូវអោយរដ្ឋាភិបាលមូលដ្ឋាន អនុម័តច្បាប់ត្រួតពិនិត្យការជួលផ្ទះ ដើម្បីដាក់កម្រិតលើម្ចាស់ផ្ទះ ពីបង្កើនអត្រាឈ្នួលផ្ទះ ចំនួន 15% ក្នុងកំឡុងពេល 3ឆ្នាំដំបូងដែលគ្មានអ្នកជួល។ |
| **សំណើ 22**<br>គំនិតផ្តួចផ្តើម អំពីអ្នកបើកបរតាមរយ: App ជាអ្នកម៉ៅការ និងគោលការណ៍ពលកម្ម | **ប្រឆាំង –** សំណើ 22 នឹងធ្វើអោយច្បាប់ AB 5 លែងមានប្រសិទ្ធភាព ហើយនឹងអនុញ្ញាតអោយ Uber និង Lyft និងក្រុមហ៊ុន ផ្តល់សេវាជិះរួមគ្នា (ride-sharing) ឯទៀត បន្តចាត់ទុកអ្នកបើកបរទាំងអស់ ជាអ្នកម៉ៅការ, មិនមែនជានិយោជិត។ អ្នកបើកបរ នឹងមិនទទួលបានប្រាក់សម្រាប់ការធ្វើការលើសម៉ោង, ប្រាក់ពេលឈឺ ឬ ការឈប់សម្រាក ដោយសារបញ្ហាគ្រួសារ, ការធានារ៉ាប់រងចំណូលពេលគ្មានការធ្វើ, ឬប្រាក់សំណងអ្នកធ្វើការ (របួសពីការងារ) នោះទេ ប្រសិនបើសំណើ ២២ នេះ បានក្លាយជាច្បាប់។ ការរាតត្បាតនៃជំងឺដែលកំពុងកើតមានឡើងជាបន្តនេះ បានធ្វើអោយអ្នកបើកបរតាមរយ: App ទាំងនោះ ក្លាយជាអ្នកធ្វើការចាំបាច់។ ច្រើនជាង 27% នៃអ្នកធ្វើការទាំងនេះ ប្រថុយទៅធ្វើការទាំងគ្រុនក្តៅ ពីព្រោះពួកគេត្រូវការប្រាក់ចំណូល, 20% គ្មានការធានារ៉ាប់រងសុខភាព, និង 15% ពឹងលើជំនួយសាធារណ:ណាម្យ៉ាង។ |
| **សំណើ 23**<br>គំនិតផ្តួចផ្តើមលើតម្រូវការសម្រាប់ឃ្លីនិកលាងឈាម | **គាំទ្រ –** សំណើលេខ 23 នឹងតម្រូវអោយមជ្ឈមណ្ឌលលាងឈាមរ៉ាំរ៉ៃ ត្រូវមានយ៉ាងហោចណាស់ នូវវត្តមានគ្រូពេទ្យម្នាក់ ដែលមានអាជ្ញាបណ្ណត្រឹមត្រូវ នៅក្នុងកំឡុងពេលថែអ្នកជំងឺ, រាយការណ៍ទាំងអស់ នូវការឆ្លងរោគដែលទាក់ទងនឹងការលាងឈាម ទៅកាន់មន្ត្រីសុខភាពរបស់រដ្ឋ, អោយបុគ្គលិកដែលទទួលបន្ទុកផ្នែករាយការណ៍នោះ ធ្វើការបញ្ជាក់អះអាង នៅក្រោមច្បាប់ ដែលអាចផ្តន្ទាទោស ចំពោះការភូតកុហកថា ព័ត៌មានដែលត្រូវបានបញ្ជូនទាំងអស់ គឺត្រឹមត្រូវ និងទទួលបានការយល់ព្រមពីក្រសួងសុខាភិបាលរបស់រដ្ឋ និងផ្តល់ការជូនដំណឹងនៅមុនពេលបិទ។ ក្នុងចំណោមជន AANHPIs មានអត្រាទ្វេដងពី ក្រុមមនុស្សដទៃទៀត ក្នុងការវិវត្តទៅជាជំងឺខ្សោយតម្រងនោម, ហើយការអាចចូលទៅព្យាបាលនៅ មជ្ឈមណ្ឌលលាងឈាម ដែលត្រូវបានត្រួតមើលយ៉ាងត្រឹមត្រូវ ប្រកបដោយក្រមសីលធម៌ និងមានការបញ្ជាក់ទទួលស្គាល់ថាត្រឹមត្រូវនោះ គឺជារឿងសំខាន់ចាំបាច់។ |
| **សំណើ 24**<br>គំនិតផ្តួចផ្តើមលើ ច្បាប់ និងភ្នាក់ងារព័ត៌មានផ្ទាល់ខ្លួនរបស់អតិថិជន | **ប្រឆាំង –** សំណើលេខ 24 នឹងប៉ះពាល់ដល់ ការការពារភាពឯកជនរបស់អតិថិជន ដោយការធ្វើវាអោយក្លាយទៅជាទំនួលខុសត្រូវរបស់អ្នកប្រើ ដើម្បីអោយគេដឹងថា គេត្រូវជ្រើសយកការមិនចូលរួម ដោយត្រូវធ្វើការកំណត់នៅលើឧបករណ៍អេឡិកត្រូនិករបស់គេ។ វាអនុញ្ញាតអោយក្រុមហ៊ុនគិតតម្លៃខ្ពស់ជាង ពីអតិថិជន ដែលជ្រើសរើសការពារភាពឯកជនរបស់គេ។ វាបង្កើតច្រកគេចពីច្បាប់ សម្រាប់ភ្នាក់ងារឥណទាន និងសាជីវកម្មទិន្នន័យ លក់ព័ត៌មានផ្ទាល់ខ្លួនរបស់ម្ចាស់ពាណិជ្ជកម្មខ្នាតតូច និងអនុញ្ញាតអោយបន្តប្រើពិន្ទុសង្កាត់ ដើម្បីសម្គាល់ពូជសាសន៍របស់មនុស្សម្នាក់ ឬ សង្កាត់ប្រជាសាស្ត្រ។ គំនិតផ្តួចផ្តើមទាំងនេះ នឹងធ្វើអោយមានការប៉ះពាល់សំខាន់ច្រើនផ្សេងគ្នា ដល់ AANHPI និងសហគមន៍ POC, អ្នកដែលពឹងអាស្រ័យលើភាពឯកជននៃទិន្នន័យ និងអាចប្រឈមនឹងបញ្ហាច្បាប់ ដោយព្រោះឋានៈអន្តោប្រវេសន៍របស់គេ និងកត្តាផ្សេងទៀត។ |
| **សំណើ 25**<br>ផ្លាស់ការលោះខ្លួនពីការជាប់ឃុំដោយប្រើប្រាក់សុទ្ធ ជំនួសដោយប្រជាមតិវាយតម្លៃហានិភ័យ | **គាំទ្រ –** សំណើលេខ 25 នឹងជំនួសប្រព័ន្ធលោះខ្លួនពីការជាប់ឃុំដោយប្រើលុយសុទ្ធ ជាមួយនឹងប្រព័ន្ធវាយតម្លៃហានិភ័យវិញ។ ចំពោះអ្នកដែលត្រូវបានកំណត់ថា មានហានិភ័យទាបដល់សុវត្ថិភាព និងការគេចខ្លួនពីការជំនុំជម្រះ នឹងត្រូវបានដោះលែងចេញពីគុក ហើយអ្នកដែលត្រូវបានកំណត់ថា មានហានិភ័យខ្ពស់ នឹងត្រូវស្ថិតនៅក្នុងគុក។ ការប៉ះពាល់ដល់សហគមន៍ AANHPI ពុំមានភាពច្បាស់លាស់ទេ, យ៉ាងណាក្តី ការបំបាត់ចោលប្រព័ន្ធលោះខ្លួនពីការជាប់ឃុំដោយប្រើលុយសុទ្ធនេះ នឹងកាត់បន្ថយចំនួនអ្នកជាប់គុក និងសំចៃប្រាក់បានរាប់ពាន់ដុល្លារជារៀងរាល់ឆ្នាំ ពីការបង់ជាប្រាក់សុទ្ធជូនតុលាការ និងអ្នកធានា ដែលយកប្រាក់ទៅដាក់សម្រាប់លោះ ខ្លួនពីការជាប់ឃុំ។ |
| **វិធានការ J**<br>ការវិនិយោគសហគមន៍ និងជម្រើសផ្សេងជំនួសការឃុំឃ្លួន<br>ការបែងចែកថវិកាអប្បបរមាសម្រាប់ខោនទី | **គាំទ្រ –** វិធានការ J បែងចែក 10%+ នៃថវិការបស់ Los Angeles អោយផ្ទាល់ដល់ការវិនិយោគសហគមន៍ និងជម្រើសផ្សេងជំនួសការឃុំខ្លួន។ ថវិកាសម្រាប់ចាយវាយក្នុងបច្ចុប្បន្ន គឺមានតែ 1% ប៉ុណ្ណោះ។ ប្រាក់ផ្គត់ផ្គង់ដែលត្រូវបានបែងចែកអោយនោះ គឺត្រូវអនុវត្តសម្រាប់រយ:ពេល 3 ឆ្នាំ នឹងត្រូវបានកំណត់អោយប្រើសម្រាប់កម្មវិធីមួយចំនួន ដូចជា ការហ្វឹកហ្វឺនការងារ, ការងារសម្រាប់អ្នកស្រុកដែលមានប្រាក់ចំណូលទាប, ច្រកទៅកាន់មូលធន សម្រាប់ពាណិជ្ជកម្មខ្នាតតូចរបស់ក្រុមមនុស្សភាគតិច, ជាមួយនឹងការផ្តោតទៅពាណិជ្ជកម្ម ដែលមានម្ចាស់ជាជនស្បែកខ្មៅ, ជំនួយថ្លៃផ្ទះ, សក្ខីបត្រសម្រាប់ទីលំនៅ, មូលធនផ្គត់ផ្គង់ គម្រោងផ្តាច់មុខ សម្រាប់សេវាស្តារសុខភាព និងច្រើនទៀត។ វិសោធនកម្មលើសុខភាព, លំនៅឋាន នឹងផ្តោតលើការផ្តល់ប្រយោជន៍ដល់ AANHPIs ជាមួយនឹងជម្រើសផ្សេងទៀត ជំនួសការឃុំខ្លួន។ |